ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១០០/១៩ - ណាហ្គាវើលដ៍
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **យូ សួនទី**
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **វ៉ែន ៣**
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត**
អាសយដ្ឋាន ៖ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១៦ ៧៩ ២៨ ៣៨
តំណាងភាគីនិយោជកចូលរួមសវនាការ៖

| | | |
|---|---|---|
| ១- | លោក សារិន ដេណូ៉ា | មេធាវី |
| ២- | កញ្ញា ម៉ៅ សំរិទ្ធារី | មេធាវី |
| ៣- | កញ្ញា កង លាប | មេធាវី |
| ៤- | លោក តេង ចេស្តា | ជំនួយការមេធាវី |
| ៥- | លោក អេង មុនីរិទ្ធ | ជំនួយការមេធាវី |
| ៦- | លោក ផេង សុភាព | ជំនួយការមេធាវី |
| ៧- | លោក ហាយ វលោក | ធនធានមនុស្ស |
| ៨- | កញ្ញា ឌី សីហា | ធនធានមនុស្ស |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត**
អាសយដ្ឋាន ៖ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១៥ ៣២ ៦០ ៣២

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

| | |
|---|---|
| ១- លោក ព្រិត សុអួត | មន្ត្រីច្បាប់ ACILS |
| ២- កញ្ញា ឈឹម ស៊ីថរ | ប្រធានសហជីព(មូលដ្ឋាន) |
| ៣- លោកស្រី ឈុន សុខា | អនុប្រធានសហជីព(មូលដ្ឋាន) |
| ៤- កញ្ញា ឈឹម សុខន | លេខាសហជីព |
| ៥- កញ្ញា ធាម គឹមលាង | សកម្មជនសហជីព |
| ៦- លោក សុខ ណារិទ្ធ | ជំនួយការច្បាប់សហជីព |
| ៧- លោក សុខ គង្គា | សកម្មជន |
| ៨- លោក ណុប កុម្ភៈ | សកម្មជន |
| ៩- លោក ជា តុលា | សមាជិក |
| ១០- លោក ស័ក្តិ សែនភក្តី | សមាជិក |
| ១១- លោកស្រី ប៉ែន ចិន្តា | សមាជិក |
| ១២- លោក រស់ សុភ័ក្រ | សមាជិក |
| ១៣- កញ្ញា Odaraka Katherine | ASM |
| ១៤- កញ្ញា គី ចាន់សុធារី | សមាជិក |
| ១៥- លោក ចំណាន កិត្តិគុណ | សមាជិក |
| ១៦- កញ្ញា ផាត់ ថារី | សមាជិក |
| ១៧- កញ្ញា សៀន សុគុណ | សមាជិក |

## **បញ្ហាក្នុងវិវាទ**

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ភាគីកម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនអនុវត្តការឈប់សម្រាកថ្ងៃបុណ្យជាតិតាមច្បាប់ស្តីពីការងារ ដោយគោរពតាមគោលការណ៍ស្ម័គ្រចិត្ត។ ដោយឡែក ភាគីនិយោជកបញ្ជាក់ថា ណាហ្គា គឺជាក្រុមហ៊ុនដំណើរការអាជីវកម្មបដិសណ្ឋារកិច្ច និងបំរើសេវាពេញ ២៤ម៉ោង ដែលពឹងផ្អែកទៅលើថ្ងៃបុណ្យ ដើម្បីទទួលបានប្រាក់ចំណូល។ ចាប់ពីថ្ងៃដំបូង នៅពេលចុះកិច្ចសន្យាការងារជាមួយបុគ្គលិកទាំងអស់ យើងធ្វើវាជាកាតព្វកិច្ចតាមសន្យា ហើយវាជាកាតព្វកិច្ចរបស់បុគ្គលិកទាំងអស់ ដែលចាំបាច់តម្រូវឱ្យបុគ្គលិកធ្វើការនៅថ្ងៃបុណ្យ និងទៅតាមកាលវិភាគ និងវេនការងារ។ បន្ថែមលើនេះទៀត បុគ្គលិកដែលធ្វើការនៅថ្ងៃបុណ្យ ទទួលបានប្រាក់ឈ្នួល ៣០០% គឺច្រើនជាងថ្ងៃធម្មតា និងទទួលបានអត្ថប្រយោជន៍ផ្សេងៗទៀត។ ដោយគោរពតាមច្បាប់ពាក់ព័ន្ធរបស់ប្រទេសកម្ពុជា ភាគីទាំងអស់ត្រូវគោរព និងត្រូវជាប់កាតព្វកិច្ចផ្លូវច្បាប់ ដោយកិច្ចសន្យាការងារ ដែលចុះហត្ថលេខារួចហើយ ជាពិសេសនោះ មានការទទួលស្គាល់ដោយបញ្ញត្តិពាក់ព័ន្ធនៃច្បាប់ស្តីពីការងារ។

២- ភាគីកម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនបញ្ឈប់ឈ្មោះ ផ្លរៀន ប៉ាស្ទីវ (Florian Pastiu) ប្រធានផ្នែកប្រតិបត្តិការកាស៊ីណូ ពីការងារ ព្រោះគាត់បានប្រព្រឹត្តិកំហុសធ្ងន់ ដោយការជេរប្រមាថ និងបៀតបៀនកេរ្តិ៍ខ្មាសដល់បុគ្គលិក ព្រមទាំងបានប្រព្រឹត្តិសកម្មភាពខុសច្បាប់ដទៃទៀត។ ដោយឡែក ភាគីនិយោជកបញ្ជាក់ថា លោក Florian Pastiu ជាអនុប្រធានជាន់ខ្ពស់ទទួលបន្ទុកផ្នែកប្រតិបត្តិកាស៊ីណូ (ហៅថា Florian) ជាសមាជិកមួយរូបនៃគណៈគ្រប់គ្រងជាន់ខ្ពស់ ហើយគាត់មិនបានរំលោភបំពាននូវវិធាន និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ។ អាស្រ័យហេតុនេះ ក្រុមហ៊ុនមិនមានហេតុផល និងមូលហេតុត្រូវបញ្ឈប់គាត់នោះឡើយ។ អាកប្បកិរិយារបស់លោក Florian វាជាការទទួលខុសត្រូវរបស់ក្រុមហ៊ុន ប៉ុន្តែ មិនមែនជាការទទួលខុសត្រូវរបស់សហជីព ដែលបានប្រព្រឹត្តទង្វើលើសដែនកំណត់នៃច្បាប់។ ការពិតទៅ លោក Florian មានសិទ្ធិប្តឹងជនណា ដែលចោទប្រកាន់គាត់ចំពោះអាកប្បកិរិយារបស់គាត់នេះ។ លោក Florian មានសិទ្ធិសេរីភាពក្នុងការចាត់វិធានការការប្តឹងបុគ្គលណាម្នាក់ ឬក្រុមណាមួយ ដែលប្រមាថគាត់ ធ្វើឱ្យគាត់ខូចខាត និងបង្ខូចកេរ្តិ៍ឈ្មោះគាត់ទៅតាមអ្វីដែលគាត់គិតថាអាចធ្វើបានក្នុងដែនសមត្ថភាពរបស់គាត់។ ក្រុមហ៊ុនមិនមានការផ្លាស់ប្តូរចំពោះតួនាទីគ្រប់គ្រងរបស់លោក Florian នៅក្នុងក្រុមហ៊ុនឡើយ។

៣- ភាគីកម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលប្រចាំខែដល់បុគ្គលិកចូលធ្វើការដំបូង ដែលបម្រើការផ្នែកល្បែង ក្នុងម្នាក់ៗ ចំនួនយ៉ាងតិច ៥០០ ដុល្លារ និងបុគ្គលិកផ្នែកសណ្ឋាគារ ចំនួនយ៉ាងតិច ៣០០ ដុល្លារ។ ដោយឡែក ភាគីនិយោជកបញ្ជាក់ថា នៅខណៈនេះក្រុមហ៊ុនសូមបដិសេធដាច់ខាត ចំពោះការទាមទារឡើងប្រាក់ខែ ខណៈដែលបច្ចុប្បន្នក្រុមហ៊ុនមានផែនការប្រាក់ខែ និងអត្ថប្រយោជន៍ផ្សេងៗ ល្អហើយ ហើយជាពិសេសក្រុមហ៊ុនបានអនុវត្តនូវផែនការផ្តល់ភាគហ៊ុនសម្រាប់បុគ្គលិក (ហៅថា គម្រោងផ្តល់ភាគហ៊ុនដល់បុគ្គលិក "ESOS" ដែលនឹងផ្តល់អត្ថប្រយោជន៍ដល់គ្រប់ផ្នែក គ្រប់កម្រិតការងារ ដែលផែនការនេះ កំពុងរង់ចាំប្រកាសជាសាធារណៈ ដែលនឹងធ្វើឡើងបន្ទាប់ពីបានអនុម័តដោយផ្សារភាគហ៊ុនហុងកុង និងម្ចាស់ភាគហ៊ុនទាំងអស់របស់ក្រុមហ៊ុននៅក្នុងកិច្ចប្រជុំទូទៅវិសាមញ្ញ ដែលនឹងប្រជុំនៅពេលសមរម្យមួយក្នុងពេលអនាគត ឆាប់ៗនេះ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨១ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ (អាណត្តិទី១៧)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះភាគីទាំងពីរមិនបានឯកភាពលើចំណុចណាមួយនឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត លេខ ១១៩៣ ក.ប/អក/វក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩។

ARBITRATION COUNCIL

**សវនាការ និង សង្ខេបនីតិវិធី**

**ទីកន្លែងសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ** ៖ ថ្ងៃព្រហស្បតិ៍ ១១កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក។

**បញ្ហានីតិវិធី៖**

នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ លើការទាមទារលក្ខខណ្ឌការងារ និងអត្ថប្រយោជន៍ចំនួន ៤ ចំណុច។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញឱ្យដោះស្រាយវិវាទការងាររួមនេះ និងបានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកធ្វើការផ្សះផ្សាចំនួន ២ លើក។ លើកទី១ នៅថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៩ និងលើកទី២ នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩។ បន្ទាប់ពីបានពិនិត្យសំណុំរឿងគ្រប់ជ្រុងជ្រោយផ្អែកតាមអង្គហេតុ និងអង្គច្បាប់រួចមក អ្នកផ្សះផ្សាបានពិនិត្យឃើញថា ចំណុចទាមទារទី១ ពាក់ព័ន្ធនឹងសំណើសុំឱ្យនិយោជកទទួលយកឈ្មោះ **ឈឹម ស៊ីថរ** ជាប្រធានសហជីពឱ្យចូលធ្វើការវិញ និងរំលឹកប្រាក់ឈ្នួលព្រមទាំងអត្ថប្រយោជន៍ផ្សេងៗ ចាប់ពីថ្ងៃព្យួរ រហូតដល់ថ្ងៃធ្វើការ ដោយបញ្ឈប់ការរើសអើងសហជីព គឺជាវិវាទបុគ្គលដែលនឹងត្រូវដោះស្រាយផ្អែកតាមស្មារតីនៃប្រកាសលេខ ៣១៨ សកបយ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីនីតិវិធីការដោះស្រាយវិវាទបុគ្គល។ ដោយឡែកចំណុចទាមទារចំនួន ៣ ចំណុចផ្សេងទៀត គឺជាវិវាទការងាររួម ដែលត្រូវបានដោះស្រាយនៅអំឡុងពេលផ្សះផ្សាចំពោះមុខភាគីវិវាទទាំងពីរដោយផ្អែកតាមស្មារតីនៃប្រកាសលេខ ៣១៧ សកបយ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០០១ ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទការងាររួម។ ចំណុចមិនសះជាចំនួន ៣ ចំណុច ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត លេខ ១១៩៣ ក.ប/អក/វក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩។

បន្ទាប់ពីបានទទួលសំណុំរឿងនេះមក ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ ២០១៩។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីកម្មករនិយោជិត និងភាគីនិយោជកមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជា ចំនួន ៣ ចំណុចនេះ នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្នុងដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ពួកគាត់មិនអាចបន្តចូលរួមសវនាការបានទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ឈ្មោះ Mike Ngai ជាប្រធានមន្ត្រីប្រតិបត្តិផ្នែកទីផ្សារនៃក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត ផ្ទេរសិទ្ធិជូនកញ្ញា ម៉ៅ សំរុទ្ធារី និងកញ្ញា កង លាប ជាមេធាវីនៅក្នុងក្រុមមេធាវី អេច.អឹម.អិល & ខន់សាល់ថិន។

២- ពាក្យសុំពិនិត្យ និងថតចម្លងសំណុំរឿង ចុះថ្ងៃអង្គារ ៩កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩។

៣- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ចុះថ្ងៃព្រហស្បតិ៍ ៤រោច ខែអស្សុជ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៩ របស់ឈ្មោះ Lee Wai Tuck Philip ប្រគល់សិទ្ធិឱ្យមេធាវី សារិន ដេណូរ៉ា និងមេធាវី ហ៊ិប សិកា។

៤- សារណាសង្ខេបនៃវិវាទការងារ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៩។

៥- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីកាពាណិជ្ជកម្មក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត លេខ MOC-88548969 ពណ.ចបព ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០២។

៦- អនុស្សារណៈ និងលក្ខន្តិកៈរបស់ក្រុមហ៊ុន ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៨២។

៧- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១០។

៨- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត លេខ ១១៩៣ ក.ប/អក/វក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩។

៩- លិខិតលេខ ៥៧២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩ របស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ជម្រាបមក លោកនាយកក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត ស្តីពីការជ្រើសរើសអាជ្ញាកណ្តាល។

១០- លិខិតប្រគល់សិទ្ធិពីសាខាក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត តែងតាំង លោក ហាយ វលាក ជាតំណាង ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៩។

១១- លិខិតលេខ ៥៧៦ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ របស់លេខា ធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល គោរពអញ្ជើញ លោកនាយកក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត ដើម្បីចូលរួមសវនាការ។

១២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួ ក្រុមហ៊ុន ណាហ្គាវើលដ៍ ចុះថ្ងៃទី០៧ និងថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩។

១៣- កស្តុតាង និងឯកសារផ្សេងៗ ដែលពាក់ព័ន្ធនឹងចំណុចវិវាទ។

១៤- គំរូកិច្ចសន្យាការងារ (កម្រិត ៥ B និងចុះក្រោម)។

១៥- ប្រកាសលេខ ១០ ស្តីពីប្រាក់បំណាច់នៃការងារដែលបានធ្វើក្នុងឱកាសថ្ងៃឈប់សម្រាកដែលត្រូវមានប្រាក់ឈ្នួល ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៩។

១៦- ប្រកាសលេខ ៣៩៩ ស្តីពីការឈប់បុណ្យដែលមានប្រាក់ឈ្នួលប្រចាំឆ្នាំ២០២០ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១២០១៩។

១៧- មាត្រា ៦៥ នៃច្បាប់ស្តីពីការងារ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧។

១៨- មាត្រា ៣១១ នៃក្រមរដ្ឋប្បវេណី។

១៩- សេចក្តីជូនដំណឹងលេខ ០៤០/១៩ ស្តីពីថ្ងៃឈប់ក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩។

២០- សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលសំណុំរឿងលេខ ០៩៣/១៥ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥។

២១- លិខិតជូនដំណឹងស្តីពីបុគ្គលិកមិនចូលធ្វើការនៅថ្ងៃបុណ្យភ្ជុំបិណ្ឌ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ ២០១៩។

២២- លិខិតជូនដំណឹងស្តីពីបុគ្គលិកមិនចូលធ្វើការនៅថ្ងៃបុណ្យភ្ជុំបិណ្ឌ (ថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែកញ្ញា) និងថ្ងៃឈប់បុណ្យបន្តបន្ទាប់ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៩។

២៣- លិខិតក្រុមហ៊ុនឆ្លើយតបសហជីពពាក់ព័ន្ធនឹងការស្នងមតិអត្ថប្រយោជន៍ក្រុមហ៊ុន និងករណីលោក Florian ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩។

២៤- លិខិតឆ្លើយតបករណីពាក់ព័ន្ធលោក Florian និងការស្ទង់មតិ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ ។

២៥- លិខិតឆ្លើយតប និងផ្តល់ព័ត៌មានបច្ចុប្បន្នភាពស្តីពីវិធានការរបស់ក្រុមហ៊ុន ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩។

២៦- របាយការណ៍ស្តីពីឥរិយាបថមិនសមរម្យរបស់លោក Florian ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩។

២៧- លិខិតបញ្ជាក់ពីទីតាំងបន្ទប់ប្រជុំតាមការស្នើសុំ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩។

២៨- លិខិតស្នើសុំបន្ទប់ប្រជុំជួបជាមួយសមាជិក ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩។

២៩- ផ្តល់ព័ត៌មានបច្ចុប្បន្នភាពស្តីពីវិធានការរបស់ក្រុមហ៊ុន-ឆ្លើយតបលិខិតសហជីពចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩។

៣០- លិខិតស្នើសុំពិភាក្សា ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩។

៣១- លិខិតឆ្លើយតបលិខិតសហជីព ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩, ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ ២០១៩។

៣២- លិខិតផ្តល់ការឆ្លើយតបចំពោះលិខិតក្រុមហ៊ុន ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩។

៣៣- លិខិតឆ្លើយតបលិខិតសហជីពស្នើសុំការប្រជុំ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩។

៣៤- លិខិតបំភ្លឺបន្ថែមពីហេតុផលមិនផ្តល់អត្តសញ្ញាណថ្នាក់គ្រប់គ្រងកណ្តាល ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩។

៣៥- លិខិតស្នើសុំប្រជុំពិភាក្សា ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៩។

៣៦- លិខិតសំដែងការព្រួយបារម្ភពីករណីដែលបានកើតឡើង ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩។

៣៧- លិខិតឆ្លើយតបពីសេចក្តីសង្ខេបចំណុចសំខាន់ៗ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩។

៣៨- លិខិតផ្តល់ព័ត៌មានបន្ថែម ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩។
៣៩- កំណត់ហេតុប្រជុំជាមួយសហជីព ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៩។
៤០- លិខិតឆ្លើយតបលិខិតសហជីព ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨, ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨។
៤១- លិខិតឆ្លើយតបលិខិតក្រុមហ៊ុន ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨, ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨។
៤២- លិខិតស្នើសហជីពផ្តល់ព័ត៌មានជាក់លាក់ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨។
៤៣- លិខិតស្នើសុំប្រជុំពិភាក្សា និងបណ្តឹងចំពោះលោក Florian ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨។
៤៤- លិខិតក្រុមហ៊ុនប្រគល់ជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពាក់ព័ន្ធនឹងភាគហ៊ុនផ្តល់ជូនបុគ្គលិក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៩។
៤៥- កំណត់ហេតុប្រជុំជាមួយថ្នាក់ដឹកនាំសហជីព ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩។
៤៦- កំណត់ហេតុប្រជុំប្រតិភូបុគ្គលិកលើកទី១២ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩។
៤៧- លិខិតក្រុមហ៊ុនឆ្លើយតបសហជីពស្តីពីព័ត៌មានបច្ចុប្បន្នភាពនៃការស្ទង់មតិ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩។
៤៨- លិខិតស្តីពីការឆ្លើយតបឱ្យពន្លឿនការស្ទង់មតិ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩។
៤៩- កំណត់ហេតុប្រជុំជាមួយសហជីព ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩។
៥០- លិខិតឆ្លើយតបបន្ទាប់ពីការប្រជុំនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩។
៥១- កំណត់ហេតុប្រជុំប្រតិភូបុគ្គលិកលើកទី១០ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩។
៥២- កំណត់ហេតុប្រជុំជាមួយសហជីពចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩។
៥៣- លិខិតក្រុមហ៊ុនឆ្លើតតបសហជីព-បញ្ជាក់កាប្រជុំលើកទី១ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៩។
៥៤- លិខិតស្នើសុំជួបប្រជុំពិភាក្សានៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការតម្លើងប្រាក់ឈ្នួលដោយមានភ្ជាប់ញត្តិគាំទ្រគំរូ និងលទ្ធផលនៃការស្ទង់មតិប្រចាំខែ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០១៩។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតលេខ ៤៣/១៩ ស.ទ.ស.ខ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ របស់សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុន ណាហ្គាវើលដ៍ គោរពជូន លេខាធិការដ្ឋានក្រុមប្រឹក្សា អាជ្ញាកណ្តាល ស្តីពីស្នើសុំជួយអន្តរាគមន៍ និងចេញបញ្ជាទៅថ្នាក់គ្រប់គ្រងក្រុមហ៊ុន ណាហ្គា វើលដ៍ ឱ្យទម្លាក់ចោលការព្យួរការងារកញ្ញា ឈឹម ស៊ីថរ ហើយអនុញ្ញាតឱ្យកញ្ញាបាន ចូលបម្រើការងារនៅកន្លែងដើមវិញ មុននឹងបើកសវនាការដោះស្រាយវិវាទមិនសះជា ជាមួយគ្នា ដោយគោរពស្មោះត្រង់ និងសុចរិត។
២- លិខិតចាត់តាំងលេខ ០៥១/១៩ ACILS ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់មជ្ឈមណ្ឌលសាមេរិកាំងសម្រាប់សាមគ្គីភាពការងារអន្តរជាតិ គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សា

ARBITRATION COUNCIL

អាជ្ញាកណ្តាល ស្តីពីចាត់តាំងលោក ព្រិត សុអួត មន្ត្រីច្បាប់ ចូលរួមដោះស្រាយវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងសំណុំរឿងលេខ ១០០/១៩។

៣- ពាក្យបណ្តឹង និងលិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩។

៤- លិខិតព្យួរការងារកញ្ញា ឈឹម ស៊ីថរ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩។

៥- លិខិតចាត់របស់កម្មករនិយោជិយនៃក្រុមហ៊ុន ណាហ្គាវើលដ៍ គោរពជូន លោកប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីសំណើសុំចាត់តាំងប្រតិភូចរចា ដើម្បីដោះស្រាយវិវាទការងាររួម នៅក្រុមហ៊ុន ណាហ្គាវើលដ៍ តាំងប្រតិភូចរចា ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩។

៦- កំណត់ហេតុស្តីពីការសាកសួរព័ត៌មានពីតំណាងកម្មករនិយោជិតនៃក្រុមហ៊ុន ណាហ្គាវលើដ៍ លីមីធីត ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ ២០១៩។

៧- បញ្ជីវត្តមានអ្នកចូលរួមផ្សះផ្សានៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៩។

៨- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩។

៩- លិខិតតវ៉ាចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៩។

១០-ពាក្យសុំតវ៉ា និងចំណាត់ការបន្ត ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៩។

១១- ញត្តគាំទ្រ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៩។

១២- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១០។

១៣- លិខិតឆ្លើយឆ្លងរវាងក្រុមហ៊ុន និងសហជីពករណីស្នើសុំកំលៃប្រាក់ខែ។

១៤- លិខិតឆ្លើយឆ្លងរវាងក្រុមហ៊ុន និងសហជីពករណីលោក Florian.

១៥- ប្រកាសលេខ ១០ សកបយ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៩ ស្តីពីប្រាក់បំណាច់នៃការងារដែលបានធ្វើក្នុងឱកាសថ្ងៃឈប់បុណ្យ ដែលត្រូវមានប្រាក់ឈ្នួល។

១៦- លិខិតលេខ ១១៦ ក.ប/វក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់ថា សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុន ណាហ្គាវើលដ៍ ជាអង្គការវិជ្ជាជីវៈមួយបានចុះបញ្ជីនៅនាយកដ្ឋានវិវាទការងារ និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ ។

១៧- លក្ខន្តិកៈសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុន ណាហ្គាវើលដ៍ បានចុះបញ្ជីលេខ ១១២១៨០៣៩៧ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨។

១៨- តារាងចំណូលក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីតរយៈពេល៥ឆ្នាំ។

១៩- លិខិតបំភ្លឺរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ណាហ្គាវើលដ៍ គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីជំហរ និងមូលហេតុដែលតំណាងកម្មករនិយោជិតមិនអាចចូលរួមសវនាការបន្ត នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩។

ក្រុមប្រឹក្សាអាជ្ញាកណ្តាល ARBITRATION COUNCIL

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត លេខ ១១៩៣ ក.ប/អក/វក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩។

៣- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៩។

៤- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត លេខ ០១៣/១៩ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ របស់នាយកដ្ឋានវិវាទការងារ។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៥៧៦ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ៤កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៥៧៧ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ៤កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩។

**អង្គហេតុ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទដែលចែងនៅក្នុងរបាយការណ៍មិនសះជារបស់នាយកដ្ឋានវិវាទការងារ ដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារ ភាគីកម្មករនិយោជិត ដែលជាដើមបណ្តឹងបានបោះបង់ចោលនូវបណ្តឹង នៅក្នុងសវនាការ។

**ហេតុផលនៃសេចក្តីសម្រេច ៖**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ ក្នុងករណីអវត្តមានរបស់ភាគីកម្មករនិយោជិតដែលជាដើមបណ្តឹងនោះ?

ប្រការ២០ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា ៖ *"...ភាគីទាំងអស់ត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម។"*

ប្រការ២១ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា ៖ *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់"*។

នៅក្នុងសំណុំរឿងមុន ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ក្នុងករណីដែលភាគីដើមបណ្តឹងបានទទួលលិខិតអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានបង្ហាញខ្លួន និងមិនចូលរួមសវនាការ។ *(សូមមើលបន្ថែមសំណុំរឿងលេខ ១៦/០៧-ឡូទូសតិ៍, លេខ ២៧/០៧-អ៊ឹម ស៊ឹង ៣-៣, លេខ*

ARBITRATION COUNCIL

*១៣៨/០៨-ម៉ាលីន, លេខ ១១/១១-ដូន តិចវ៉ាយល៍, លេខ ១៣១/១២-ម៉ាស្ទ័រ & វ៉ៃហ្វង, លេខ ១០៨/១៣-អាត់តូ និងលេខ ៣៣២/ ១៤-ជី & ខេ ហ្គាមេន)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

យោងតាមអង្គហេតុ ភាគីកម្មករនិយោជិតបានមកចូលរួមសវនាការ តាមការអញ្ជើញ។ ប៉ុន្តែ នៅក្នុងដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ពួកគាត់មិនអាចបន្តចូលរួមសវនាការសួរកេអង្គសេចក្តីបានទេ ដោយហេតុថា ចំណុចទាមទារឱ្យប្រធានសហជីពចូលធ្វើការវិញ មិនត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលដើម្បីដោះស្រាយទេ។ ហេតុនេះ ភាគីកម្មករនិយោជិតសម្រេចចិត្តមិនចូលរួមក្នុងសវនាការនេះទេ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតដែលជាភាគីដើម បណ្តឹងបានទទួលការអញ្ជើញឱ្យមកចូលរួមសវនាការត្រឹមត្រូវរួចហើយ ប៉ុន្តែ ពួកគាត់បានត្រឹមតែមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលនៅថ្ងៃសវនាការប៉ុណ្ណោះ ដោយបានបដិសេធចូលរួមសវនាការនេះ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការមិនចូលរួមសវនាការនេះ គឺជាទង្វើដែលផ្ទុយពីប្រការ២០ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល។ម្យ៉ាងវិញទៀត ទង្វើនេះ ត្រូវបានចាត់ទុកថា ភាគីកម្មករនិយោជិតសម្រេចមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្របតាមខ្លឹមសារប្រការ២១ នៃប្រកាសលេខ ០៩៩ ខាងលើទេ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ១០០/១៩-ណាហ្គាវើលដ៍ លីមីធីត នេះ។

## សម្រេច

បញ្ចប់ដំណើរការអាជ្ញាកណ្តាលនៃសំណុំរឿងលេខ ១០០/១៩-ណាហ្គាវើលដ៍ លីមីធីត។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **យូ សួនធី**

ហត្ថលេខា ៖ ------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖**

ឈ្មោះ ៖ **ម៉ែន ពៅ**

ហត្ថលេខា ៖------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល ៖**

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា ៖ ------------------------------

THE ARBITRATION COUNCIL